# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំអូស្ត្រាលី

## សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាសូមជម្រាបបងប្អូនពលរដ្ឋខ្មែរជ្រាបថា ថ្មីៗនេះមានសារព័ត៌មាន បណ្តាញសង្គម ក្រុមហ៊ុនឯកជន និងបុគ្គលមួយចំនួនបានដើរបំផុសបំផុលផ្តល់ពត៌មានពុំច្បាស់លាស់ ឬបំភ្លៃការពិតក្នុងចេតនាបោកប្រាស់ជ្រើសរើសពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី ( Australia ) ក្រោមគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មី ( Australian Agriculture Visa ) របស់ប្រទេសអូស្ត្រាលី។

ករណីនេះ ដើម្បីជៀសវាងការចាញ់បោកជនខិលខូចឆ្លៀតឱកាស ស្ថានទូតសូមបំភ្លឺជូនថាបច្ចុប្បន្ន រដ្ឋាភិបាលអូស្ត្រាលី (ក្រសួងការបរទេស មហាផ្ទៃ និងក្រសួងកសិកម្មអូស្ត្រាលី) កំពុងពិភាក្សានៅឡើយលើការរៀបចំគម្រោងទិដ្ឋាការ "កសិកម្ម" ថ្មី ជាមួយនឹងការកំណត់លក្ខខណ្ឌផ្សេងៗក្នុងការទទួលបានទិដ្ឋាការនេះ។ គម្រោងទិដ្ឋាការកសិកម្មថ្មីនេះ នឹងផ្តល់ឱកាសដល់ពលរដ្ឋប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាចមកធ្វើការនៅប្រទេសអូស្ត្រាលីលើវិស័យកម្ម រួមទាំងឧស្សាហកម្មកែច្នៃសាច់ផងដែរ (Agriculture sector including meat processing) ជាមួយនឹងការផ្តល់ឱកាសអាចស្នើសុំសិទ្ធរស់នៅអចិន្ត្រៃយ៍ ក្នុងករណីពលករនោះបំពេញបានតាមលក្ខខណ្ឌនិងមានតម្រូវការជាក់ស្តែងពីរដ្ឋាភិបាលអូស្ត្រាលី។ តាមគម្រោង ទិដ្ឋាការថ្មីនេះនឹងពិភាក្សាចប់សព្វគ្រប់នៅចុងខែកញ្ញា ឆ្នាំ ២០២១ ខាងមុខ។ ជាមួយគ្នានេះ **រដ្ឋាភិបាលអូស្ត្រាលីនឹងធ្វើការពិភាក្សាចរចារទ្វេភាគីជាមួយប្រទេសដៃគូរមួយចំនួននៅក្នុងតំបន់លើគម្រោងទិដ្ឋាការថ្មី។**

ស្ថានទូតសូមជម្រាបជូនបងប្អូនផងដែរថា ក្រោមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកទីផ្សារការងារជូនពលករខ្មែរ កន្លងមកស្ថានទូតបានខិតខំស្វះស្វែងរកទីផ្សារការងារជូនបងប្អូនខ្មែរទាំងនៅប្រទេសអូស្ត្រាលី ក៏ដូចជាប្រទេសនូវែលហ្សេឡង់ តាមរយៈការជួបពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលប្រទេសនិមួយៗជាបន្តបន្ទាប់។ ចំពោះគម្រោងទិដ្ឋាការកសិកម្មថ្មីនេះ ក្រោមការណែនាំដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហការគាំទ្រពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ស្ថានទូតបានត្រៀមខ្លួនជាស្រេចក្នុងការបន្តជួបចរចារកទីផ្សារការងារជូនពលរដ្ឋខ្មែរជាមួយរដ្ឋាភិបាលអូស្ត្រាលី។

ស្ថានទូតសូមបញ្ជាក់ជាថ្មីថា មកទល់ពេលនេះគម្រោងទិដ្ឋាការកសិកម្មនេះកំពុងស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ ហើយរដ្ឋាភិបាលអូស្ត្រាលីនៅពុំទាន់សម្រេចថា នឹងផ្តល់ទិដ្ឋាការប្រភេទនេះជូនកម្ពុជា ឬប្រទេសណាមួយនៅឡើយទេ។ ហេតុនេះ ស្ថានទូតស្នើបងប្អូនប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយព័ត៌មានពីការជ្រើសរើស និងការបញ្ជូនពលករខ្មែរមកធ្វើការនៅប្រទេសអូស្ត្រាលី ដោយទីភ្នាក់ងារជ្រើសរើស បុគ្គល ឬអង្គភាពណាមួយ។

ព័ត៌មានផ្លូវការជុំវិញវឌ្ឍនភាពគម្រោងទិដ្ឋាការកសិកម្មថ្មីនេះ បងប្អូនអាចតាមដានលើគេហ៍ទំព័រផ្លូវការរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ស្ថានទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី ( https://www.embassyofcambodia.ogr.au ) ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេសមេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃពុធ ០៩ រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
កង់បេរ៉ា ថ្ងៃទី 01 ខែ កញ្ញា ឆ្នាំ ២០២១

5 Canterbury Crescent Deakin ACT 2600, Tel: (02) 6273 4064
E-mail: Cambodianembassy@ozemail.com.au Website: www.embassyofcambodia.org.au